ប្រការ ២ : លោកឧកញ៉ា លី យ៉ុងផាត់ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ៨៤ សសរ

## ស្តីពីការបង្កើតគណកម្មការដោះស្រាយបញ្ហាបាតុភាពព្រំដែន កម្ពុជា-ថៃតំបន់អូរជ្រៅ ខេត្តបន្ទាយមានជ័យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៥៧ សសរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណកម្មការដោះស្រាយបាតុភាពបញ្ហាដីធ្លី នៅតាមបណ្តាខេត្ត - ក្រុង ទូទាំងប្រទេស
- យោងតាមស្មារតីនៃកិច្ចចរចារ នាថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០០០ រវាងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងថៃ

### សំរេច

ប្រការ ១ : បង្កើតគណកម្មការដោះស្រាយបញ្ហាបាតុភាពព្រំដែនកម្ពុជា- ថៃ តំបន់អូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ជុំ ភារណាល់ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាប្រធាន

២-ឧត្តមសេនីយ៍ទោ សិទ្ធ ឌី មេបញ្ជាការរងកងទ័ពជើងគោក ជាអនុប្រធាន

៣-ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៤-ឯកឧត្តម ថាច់ ឃន អភិបាលខេត្តបន្ទាយមានជ័យ ជាសមាជិក

៥-លោក លឹម ទាំន់ អគ្គនាយករងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

៦-លោក ហួន សាវ៉ាង តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាសមាជិក

៧-លោក ក្រុយ ទីវគ្ស ប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាលក្រសួងមហាផ្ទៃ ជាសមាជិក

៨-លោក យ៉ា ឡេងឃាត់ ជំនួយការទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ច :

-ចុះស្រាវជ្រាវ និង លើកវិធានការណ៍ដោះស្រាយអោយមានប្រសិទ្ធភាពនូវរាល់បាតុភាព ដែលកើតមានឡើងនៅ តាមបណ្តោយព្រំដែន កម្ពុជា- ថៃ តំបន់អូរស្មាច់ ខេត្ត បន្ទាយមានជ័យ

-ពិគ្រោះពិភាក្សាជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីថៃ ដើម្បីដោះស្រាយនូវបណ្តាបញ្ហាដែលកើតចេញជាទំនាស់នៅតំបន់អូរស្មាច់ ដោយសន្តិវិធី ៖

-ធ្វើរបាយការណ៍ អំពីវិធានការដោះស្រាយ និងលទ្ធផលនៃការងារខាងលើជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣** : សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះអោយទទួលបានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## ៣-ផែនការណែនាំ

រាជធានីភ្នំពេញ ,ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០០

### ផែនការណែនាំលេខ ០៦ ផកណ
### ស្តីពីការរៀបចំព្រះរាជពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មី
### របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
### ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងទិវាប្រកាសរដ្ឋធម្មនុញ្ញ
### និងពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ

***

★ ថ្ងៃទី ២៤ កញ្ញា ឆ្នាំ ២០០០ គឺជាបុណ្យខួបលើកទី ៧ នៃការគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង ទិវាប្រកាសរដ្ឋធម្មនុញ្ញ ។